**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ធំ**

កំពង់ធំ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

**រដ្ឋបាលខេត្តកំពង់ធំ** សូមជម្រាបជូនប្រជាពលរដ្ឋដែលរស់នៅតាមបណ្តោយដងស្ទឹងសែន និងតំបន់ងាយរងគ្រោះមួយចំនួនឲ្យបានជ្រាបថា៖ ដោយយោងតាមការព្យាករណ៍របស់ក្រសួងធនធានទឹក និងឧតុនិយម និងការតាមដានលើស្ថានភាពអាកាសធាតុកន្លងមក ខេត្តកំពង់ធំបាននឹងកំពុងទទួលរងឥទ្ធិពលសម្ពាធទាបចាប់ពីថ្ងៃទី ២៥-២៦-២៧ ខែកក្កដា ឆ្នាំ ២០១៧ នៅតំបន់ទំនាបកណ្តាល ផ្ទៃមេឃនឹងមានពពកច្រើនដេរដាស មានភ្លៀង ផ្គរ ពីមធ្យមទៅច្រើន ពិសេស នៅក្នុងខេត្តកំពង់ធំ ដែលមានខ្យល់កន្ត្រាក់ល្បឿនពី ១២-១៤m/s ។ ដោយមានភ្លៀងធ្លាក់ច្រើន កត្តានេះបានធ្វើឲ្យទឹកស្ទឹងសែនកើនឡើងខ្លាំង បើគិតត្រឹមថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១៧ នេះ ទឹកមានកម្រិតកម្ពស់ ១៣.០៧ម៉ែត្រ ដែលកម្រិតកម្ពស់ទឹកត្រូវប្រកាសឲ្យមានការប្រុងប្រយ័ត្ននៅកម្រិត ១៣.៥០ ម៉ែត្រ ។ យោងតាមការព្យាករណ៍ ទឹកភ្លៀងនឹងបន្តធ្លាក់ពីកម្រិតបង្គួរទៅច្រើនរហូតដល់ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៧ ដែលអាចជាការព្រួយបារម្ភ ។

ដើម្បីធានាសុវត្ថិភាព និងបង្ការគ្រោះមហន្តរាយជាយថាហេតុ សូមបងប្អូនប្រជាពលរដ្ឋក្នុងខេត្តជាពិសេសនៅតាមបណ្តោយដងស្ទឹងសែនមេត្តាប្រុងប្រយ័ត្នខ្ពស់ និងស្វែងរកទីទួលសុវត្ថិភាពដែលនៅជិត ចៀសវាងគ្រោះថ្នាក់ផ្សេងៗ កើតឡើង ប៉ះពាល់ដល់អាយុជីវិត និងខាតបង់ទ្រព្យសម្បត្តិជាដើម ។ ក្នុងករណីពុកម៉ែ បងប្អូនជួបគ្រោះទឹកជំនន់ សូមមេត្តាយកការណ៍ និងផ្តល់ព័ត៌មានឲ្យបានរហ័សមកភូមិ ឃុំ ស្រុក ឬខេត្តជាបន្ទាន់ ដើម្បីឲ្យអាជ្ញាធរមានលទ្ធភាពចាត់វិធានការការពារ សង្គ្រោះបានទាន់ពេលវេលា ។

**រដ្ឋបាលខេត្ត** សង្ឃឹមយ៉ាងមុតមាំថា ពុកម៉ែ បងប្អូន ប្រជាពលរដ្ឋទាំងអស់នឹងមានការប្រុងប្រយ័ត្នបង្កើនការយកចិត្តទុកដាក់ខ្ពស់ចំពោះស្ថានភាពទឹកស្ទឹងសែនដែលកំពុងបន្តហក់ឡើងនាពេលនេះ និងចូលរួមសហការជាមួយអាជ្ញាធរដែនដីក្នុងការបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដោយទឹកជំនន់នេះមានប្រសិទ្ធភាពខ្ពស់ ។

**រដ្ឋបាលខេត្ត**